雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团

# ប្រទេសចិន-ខេត្តយូនណាន

ប្រចាំថ្ងៃ

YUNNANEXPRESS
english.yunnan.cn

ឆ្នាំទី 24 លេខ 6969 ថ្ងៃសុក្រ ទី 04 ខែមីនា ឆ្នាំ 2016

## ខេត្តយូណាននឹងឈានចូលទៅក្នុងសម័យផ្លូវដែកល្បឿនលឿននៅចុងឆ្នាំនេះ



ការដ្ឋាននៃការសាងសង់ផ្លូវដែកល្បឿនលឿន សៀងហៃ-គុនមិញ នៅខេត្តយូណានកំពុងតែប្រញឹក (រូបថត ដោយLi Yinfa)

**(បណ្ដាញព័ត៌មានទូរទស្សន៍ CCTV)**

យោងតាមសេចក្ដីរាយការណ៍ពីឆាណែលព័ត៌មាននៃទូរទស្សន៍CCTV ចិនថា នៅចុងឆ្នាំនេះកំណាត់ផ្លូវដែកក្នុងខេត្តយូនណាននៃផ្លូវរថភ្លើងល្បឿនលឿនសៀងហៃគុនមីញ និងកំណាត់ផ្លូវដែកយូនណានក្វាំងស៊ី នឹងបើកដំណើរការជាផ្លូវការ ។ នៅពេលនោះ បណ្ដាញផ្លូវដែកចិនដែលយក "ទទឹង៤ បណ្ដោយ៤" ជាគ្រោងឆ្អឹងនោះ នឹងដំណើរការទាំងស្រុង ។

ផ្លូវរថភ្លើងល្បឿនលឿនសៀង-ហៃគុនមីញមានប្រវែង២.២៦៤ គីឡូម៉ែត្រ ជាផ្លូវរថភ្លើងល្បឿនលឿនវែងជាងគេតាមទិសខាងកើតឆៀងខាងលិចដែលចែកជាកំណាត់ផ្លូវដែកចំនួន៣ គឺកំណាត់ផ្លូវដែកសៀងហៃ-ហាងចូវកំណាត់ផ្លូវដែកហាងចូវឆាងសានិងកំណាត់ផ្លូវដែកឆាងសាគុន-មីញ ។ កំណាត់ផ្លូវដែកក្នុងយូនណាននៃផ្លូវរថភ្លើងល្បឿនលឿនសៀងហៃគុនមីញ មានប្រវែង១៨៤,៧ គីឡូម៉ែត្រ វានឹងកែប្រែប្រវត្តិសាស្ត្រនៃខេត្តយូនណានដែលគ្មានរថភ្លើងល្បឿនលឿន ។ បើធ្វើដំណើរពីគុនមីញទៅដល់ទីក្រុងប៉េងកាំង និងសៀងហៃដោយជិះរថភ្លើងល្បឿនលឿន គឺត្រូវការតែរយៈពេល៨ទៅ១០ម៉ោងប៉ុណ្ណោះ ។

ក្រៅពីផ្លូវរថភ្លើងល្បឿនលឿនសៀងហៃគុនមីញផ្លូវរថភ្លើងល្បឿនលឿនយូនណានក្វាំងស៊ីក៏នឹងបើកដំណើរការដំណាលគ្នាក្នុងចុងឆ្នាំនេះ។ រថភ្លើងល្បឿនលឿនយូនណានក្វាំង-ស៊ីគឺជាផ្លូវដែកសំខាន់ជាងគេពីទីក្រុងគុនមីញទៅទីក្រុងណាននីងដែលនឹងមានល្បឿន២០០គីឡូម៉ែត្រនៅក្នុងមួយម៉ោង ។ ក្រោយពីការបើកដំណើរការធ្វើដំណើរពីគុនមីញទៅដល់ទីក្រុងណាននីង គឺត្រូវការតែ៤ម៉ោង រីឯទៅដល់ ទីក្រុងក្វាំងចូវគឺត្រូវការតែ៧ម៉ោង នឹងសំចៃ១០ម៉ោងបើប្រៀបធៀបនឹងសេវាកម្មនាពេលសព្វថ្ងៃនេះដែលត្រូវការ១៧ម៉ោង ៕

## ប្រទេសចិននឹងបង្កើតហាងលក់ទំនិញរួចពន្ធចំនួន១៨កន្លែង

**សិនអឹង(ទីភ្នាក់ងារស៊ីនហួរ)**

បច្ចុប្បន្ននេះ ប្រទេសចិនបានអនុម័តដើម្បីបន្ថែមហាងលក់ទំនិញរួចពន្ធចំនួន១៨កន្លែងនៅទីក្រុងគុនមីញ ក្វាំងចូវ ហាងចូវនិងសិនចឹនជាដើម ។

យោងតាមសេចក្ដីប្រកាសរួមគ្នាមួយពីក្រសួងហិរញ្ញវត្ថុក្រសួងពាណិជ្ជកម្មអគ្គរដ្ឋបាលគយអគ្គរដ្ឋបាលគ្រប់គ្រងពន្ធ និងអគ្គរដ្ឋបាលទេសចរណ៍ប្រទេសចិនបានឱ្យដឹងថា ចាប់តាំងពីថ្ងៃទី១៨ខែកុម្ភៈកន្លងមកប្រទេសចិននឹងបន្ថែមហាងលក់ទំនិញរួចពន្ធបន្ថែមប្រភេទទំនិញ និងបង្កើនបរិមាណប្រាក់នៃការទិញទំនិញដើម្បីបំពេញតម្រូវការខាងទិញទំនិញក្នុងប្រទេសបន្ថែមជម្រើសនៃការទិញទំនិញ និងធ្វើឱ្យប្រជាជន ចិនទិញទំនិញបរទេសកាន់តែ ស្រួលជាង ។

លើកនេះ ប្រទេសចិននឹងបង្កើតហាងលក់ទំនិញរួចពន្ធចំនួន១៣នៅច្រកនៅព្រលានយន្តហោះដូចជា ព្រលានយន្តហោះឆាងស្វុយនៃទីក្រុងគុនមីញ ព្រលានយន្តហោះប៉ៃយន់នៃទីក្រុងក្វាំងចូវ ព្រលានយន្តហោះស្យាវសាននៃទីក្រុងហាងចូវ ព្រលានយន្តហោះស្វាំងលីវនៃទីក្រុងឆឹងដូ ព្រលានយន្តហោះលីវធីងនៃទីក្រុងឈាងដាវ ព្រលានយន្តហោះលូខូវនៃទីក្រុងណានជីងព្រលានយន្តហោះប៉ាវអាននៃទីក្រុងសិនចឹន ព្រលានយន្តហោះចាំងពៃនៃទីក្រុងឆុងឈាងព្រលានយន្តហោះពានហៃនៃទីក្រុងធានជានព្រលានយន្តហោះចូវស្វុយជីនៃទីក្រុងដាលានព្រលានយន្តហោះថាវស្យេននៃទីក្រុងសឹនយ៉ាំងព្រលានយន្តហោះស្យេនយ៉ាំងនៃទីក្រុងស៊ីអាន និងព្រលានយន្តហោះទីអ្វូភូនៃទីក្រុងអ៊ូរ៉ុំឈី និងបង្កើតហាងលក់ទំនិញរួចពន្ធចំនួន៦នៅច្រកឯទៀតដូចជា ច្រកហ្វឹធានហ្វាំងកាំង សាតុច្ចូ និងអ្វនជានទូនៃទីក្រុងសិនចឹន ច្រកចាខូវនៃទីក្រុងជូហៃនិងច្រកហីហឺនៃទីក្រុងហីហឺ។

សេចក្ដីប្រកាសដដែលបានបន្ថែមថា ផែនការនេះនឹងបង្កើនបរិមាណប្រាក់នៃការទិញទំនិញរបស់អ្នកចូលដែនដល់ទៅ៨.០០០យ័នចិនពីមុនបរិមាណប្រាក់នៃការទិញទំនិញរបស់អ្នកចូលដែនមានតែ៥.០០០យ័នប៉ុណ្ណោះ ៕

## "ស្នាមញញឹមអង្គរ" គឺនៅតែអស្ចារ្យ

**ដោយៈលីវ ស្យាវ**

នៅពេលដែលព្រះអាទិត្យបានលិចទៅពីស្រមោលអង្គរវត្តកន្លែងគួរឱ្យទៅទស្សនាវប្បធម៌ខ្មែរនៅពេលយប់ជាងគេ គឺទៅមើលល្ខោន"ស្នាមញញឹមអង្គរ"នៅមជ្ឈមណ្ឌលពិព័រណ៌អង្គរ ។

ក្នុងរូបភាពធំស្អាតដែលបង្កើតដោយសិល្បៈLED សម័យទំនើបអ្នកមើលហាក់ដូចជាបានឆ្លងកាត់រាប់រយឆ្នាំ ហើយបានមកដល់សម័យអង្គរពិតមែន ។ ជួរទាហានដ៏មហាអស្ចារ្យពន្លឺទានរាជវាំងដ៏ប្រិមប្រិយរបាំទេពអប្សរដ៏ស្រស់ស្អាតរបាំក្ងោកនិងព្រះសិវៈបានបង្ហាញពីទម្រង់សិល្បៈដ៏ស្អាតតំណាងឱ្យឆាយានៃវប្បធម៌ប្រទេសកម្ពុជា ។

"ស្នាមញញឹមអង្គរ" គឺជាគំរូប្រកបដោយជោគជ័យមួយសម្រាប់កិច្ចសហប្រតិបត្តិការវប្បធម៌រវាងប្រទេសចិននិងកម្ពុជា ។ នាឆ្នាំ២០១០ ក្រុមហ៊ុនយូនណានវិនិយោគឧស្សាហ-កម្មវប្បធម៌គ្រុបបានបង្កើតល្ខោន"ស្នាមញញឹមអង្គរ"នៅខេត្តសៀមរាប ។ តាំងពីការសម្ដែងលើកដំបូងនៅថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ២០១១រៀងមកដល់ថ្ងៃទី៣១ខែធ្នូឆ្នាំ២០១៥"ស្នាមញញឹមអង្គរ"ត្រូវបានសម្ដែង១.៩២៣ដង មានអ្នកមើលចំនួនប្រមាណជា៨៧៣ពាន់នាក់មកពី៥៦ប្រទេស ហើយបានចំណូលជាង១៩៦ លានយ័ន ។



ការសម្ដែងរបាំ ស្នាមញញឹមអង្គរ នៅខេត្តសៀមរាប (រូបថតដោយYang Zheng)

លោកថាវ កួស្យាំង ប្រធាននៃយូនណានវិនិយោគឧស្សាហកម្មវប្ប-ធម៌គ្រុបបានអះអាងថា""ស្នាមញញឹមអង្គរ"បានបង្កើតនូវកំណត់ត្រាជាច្រើនណាស់ ដូចជាបានសម្ដែងយ៉ាងយូរជាងគេមានអ្នកមើលច្រើនជាងគេមានចំណូលច្រើនជាងគេជាដើម ។ កំណត់ត្រាទាំងនេះគឺមកពីយើងបានរកឃើញដល់របៀបអភិវឌ្ឍន៍ដ៏សមល្មមមួយ"។

ក្នុងរយៈពេល៥ឆ្នាំកន្លងផុតទៅនេះការសម្ដែងលើកទីមួយនៃប្រទេសចិនដែលបានសម្ដែងនៅបរទេស "ស្នាមញញឹមអង្គរ"បានបង្ហាញពីភាពស្រស់ប្រិមប្រិយនៃសម័យអង្គរ ហើយក៏បានទទួលការកោតសរសើរខ្លាំងពីសំណាក់អ្នកមើលពីគ្រប់ប្រទេស។

លោកថាវ កួស្យាំងបានណែនាំថា មហោស្រព"ស្នាមញញឹមអង្គរ"មានកន្លែងអង្គុយជាង៨០០ រាល់ថ្ងៃនឹងសម្ដែង១ឬ២ដងនៅក្នុងមួយថ្ងៃ ។ ក្រៅពីនេះ ក្រុមហ៊ុននៅបានផ្ដល់សេវាភោជនីយសំខាន់ផ្ដល់ម្ហូបអាហារខេត្តយូនណាន ។ ភោជនីយដ្ឋាននេះគឺនៅជាប់នឹងមហោស្រពមានកន្លែងអង្គុយចំនួន៨០០ គឺជាអាហារប៊ូហ្វេទេស-ចរណ៍ចិនធំបំផុតនៅតំបន់អង្គរ ។

សព្វថ្ងៃនេះ "ស្នាមញញឹមអង្គរ" មិនគ្រាន់តែជាកិត្តិនាមវប្បធម៌មួយនៃប្រទេសកម្ពុជាប៉ុណ្ណោះទេប៉ុន្តែផ្ទាំងទស្សនីយភាពនេះថែមទាំងជាគំរូប្រកប ដោយជោគ-ជ័យមួយសម្រាប់កិច្ចសហប្រតិបត្តិការវប្បធម៌រវាងប្រទេសចិន និងកម្ពុជា ៕

## លោកមី ម៉ាន: របាំជាជីវិតរបស់ខ្ញុំ

**លីវ ជឺយូ**

នៅ "ដាងស្ទីរបាំស្ទូឌីយោ" ដែលស្ថិតនៅផ្លូវប៉ាវសានទីក្រុងគុនមីញ ពួកយុវវ័យក្មេងៗកំពុងពិភាក្សា និងហាត់ដោយរីករាយនូវរបាំដែលទើបតែរៀន ។ មានមនុស្សជាច្រើនមករៀនរបាំនៅដាងស្ទីរបាំស្ទូឌីយោដោយសារតែទីនោះមិនគ្រាន់តែធ្វើឱ្យពួកគេចូលចិត្តបរិយាកាសនៃស្ទូឌីយោនេះប៉ុណ្ណោះទេ ពួកគេថែមចង់ស្គាល់ម្ចាស់នៃស្ទូឌីយោនេះ គឺលោកមីម៉ានផងដែរ។ លោកមីម៉ាន សញ្ជាតិបារាំងមិត្តភក្តិរបស់លោកចូលចិត្តហៅគាត់ "ឡោមី" លោកមកដល់ទីក្រុងគុនមីញ៨ឆ្នាំហើយ គឺជា "មនុស្សគុនមីញចាស់" ពេញលេញម្នាក់។

នៅពេលចូលរៀនសកលវិទ្យាល័យ លោកមកដល់ប្រទេសចិនដោយធ្វើជានិស្សិតផ្លាស់ប្ដូរ។ ក្រោយពីការចូលរៀនរយៈពេលមួយឆ្នាំនៅទីក្រុងសៀងហៃ លោកបានជ្រើសរើសទីក្រុងគុនមីញពីទីក្រុងឆឹងដូ ស៊ីអាន និងគុនមីញ ដើម្បីបន្តការសិក្សា២ឆ្នាំទៀតនៅប្រទេសចិន។ លោកបានអះអាងថា "ការជ្រើសរើសទីក្រុងគុនមីញ សំខាន់មកពីខ្ញុំចូលចិត្តធាតុអាកាសនៃទីក្រុងគុនមីញ" ។

លោកមីម៉ានចូលចិត្តរបាំហ៊ីបហបតាំងពីកុមារមក ។ ក្រោយបានមកដល់ទីក្រុងគុនមីញ មីម៉ានបានស្គាល់ក្រុមរបាំដាងស្ទី ហើយតែងតែរាំជាមួយគ្នានឹងក្រុមរបាំនេះ ពួកគេក៏ក្លាយជាមិត្តភក្តិល្អ។ មិនយូរប៉ុន្មានលោកមីម៉ានគិតថា "ហេតុអ្វីយើងមិនយករបាំជាអាជីពមួយ?" ។ ក្រោយពីការរៀបចំពីលោកមីម៉ាននិងមិត្តភក្តិលោក នៅឆ្នាំ២០០៩ ក្រុមរបាំរបស់គេបានជ្រើសរើសផ្ទះមួយ ហើយបង្កើត "ដាងស្ទីរបាំស្ទូឌីយោ" ឡើងជាផ្លូវការ។ ដោយសារបានផ្ដល់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈបែបអឺរ៉ុប សព្វថ្ងៃនេះស្ទូឌីយោរបស់លោកមានសិក្ខាកាមចំនួន២០០ ដល់៣០០នាក់ មករៀនរបាំនៅក្នុងដាងស្ទីរបាំស្ទូឌីយោរាល់ថ្ងៃ។ លោកបានអះអាងថា"មនុស្សរៀនរបាំហ៊ីបហបកាន់តែច្រើនឡើងៗ នេះមកពីមានឪពុកម្ដាយកាន់តែច្រើនយល់ព្រមឱ្យកូនរបស់គេទៅរៀនរបាំហ៊ីបហប" ។ លោកបន្ថែមថា ការអភិវឌ្ឍនៃការបណ្ដុះបណ្ដាលរបាំហ៊ីបហបធ្វើឱ្យលោកមើលឃើញដល់ការកែប្រែនៃគំនិតនិងរបៀបរស់នៅនៃប្រជាជនគុនមីញ។

សិល្បៈនៃជនជាតិភាគតិចខេត្តយូនណាន និងរបាំរបស់លោកមីម៉ានក៏បានកើតប្រតិកម្មគីមី ។

លោកបានអះអាងថា "របាំវប្បធម៌នៃជនជាតិភាគតិចខេត្តយូនណានគឺជារតនសម្បត្តិមួយសម្រាប់យើង ។ នៅក្នុងស្ទូឌីយោយើង មានគ្រូច្រើននាក់គឺជាមនុស្សយូនណាន ហើយធ្លាប់រៀនរបាំជាជំនាញ ហេតុនេះពួកគេតែងតែបង្កើតរបាំដោយផ្សំរបាំជនជាតិយូនណានចូលក្នុងរបាំហ៊ីបហប។" លោកមីម៉ានបន្ថែមថា នៅឆ្នាំ២០១៣ ក្រុមរបាំដាងស្ទីបានបង្កើតរបាំ "ខ្យល់និងទឹក" ដោយសហការជាមួយនឹងក្រុមរបាំមួយនៃប្រទេសបារាំង ដែលជារបាំមួយបានផ្សំរបាំប្រពៃណីខេត្តយូនណាន និងរបាំហ៊ីបហបពេលសម័យ។ "ខ្យល់និងទឹក" ត្រូវបានសម្ដែងនៅទីក្រុងក្នុងប្រទេសចិនដូចជាគុនមីញ ឆឹងដូនិងឆុងឈាងជាដើម ហើយទៅសម្ដែងនៅទីក្រុងចំនួនជាង៣០នៃប្រទេសបារាំង បានទទួលចំណូលចិត្តខ្លាំងណាស់ពីអ្នកមើលក្នុង និងក្រៅប្រទេស។



លោកមីម៉ាន (រូបថតនៅលំដាប់ទី៤ រាប់ពីឆ្វេង) ថតរូបជាមួយនឹងមិត្តភ័ក្ររបស់លោក (រូបថតដោយ Liu Ziyu)

លោកមីម៉ានមានអារម្មណ៍ថាក្នុងរយៈពេល៨ឆ្នាំនេះ ពិតមែនពិបាកណាស់ក្នុងការបង្កើតអាជីពខ្លួន ប៉ុន្តែសំណាងណាស់ លោកមានក្រុមសាមគ្គីមួយ ហេតុនេះ លោកនិយាយដោយរីករាយថា "ការជ្រើសរើសស្នាក់នៅក្នុងទីក្រុងគុនមីញ គឺមិនខុសទេ"។ តាមពិត ដោយសាររបាំនេះ លោកមិនគ្រាន់តែបានស្គាល់មិត្តភក្តិជាច្រើនប៉ុណ្ណោះទេ ប៉ុន្តែនៅបានស្គាល់សង្សាររបស់លោកថែមទៀត។ ឥឡូវនេះឪពុកម្ដាយលោកមីម៉ានតែងតែមកលេងលោកនៅទីក្រុងគុនមីញ ។ គុនមីញក៏ក្លាយជាផ្ទះថ្មីមួយរបស់លោកមីម៉ាន។

មិនយូរប៉ុន្មាននេះ អាជីពរបាំរបស់លោកមីម៉ានបានបន្ថែមសកម្មភាពថ្មីមួយទៀត។ ថ្ងៃចូលឆ្នាំថ្មីឆ្នាំ២០១៦ សមាជិកមួយចំនួននៃ "ដាងស្ទីរបាំស្ទូឌីយោ" បានមកដល់សាលាបឋមសិក្សាសៀនយៀង ដើម្បីអបអរសាទរបុណ្យចូលឆ្នាំថ្មីឆ្នាំថ្មីគ្រិស្តសករាជ ហើយបង្រៀនកូនសិស្សរាំរបាំហ៊ីបហប។ លោកបាននិយាយថា "ការចូលរួមសកម្មភាពសាធារណៈឱ្យកាន់តែច្រើន ដើម្បីឱ្យមនុស្សកាន់តែច្រើនស្គាល់របាំហ៊ីបហប នេះជាគោលដៅថ្មីមួយរបស់ខ្ញុំ" ។

លោកបានបញ្ជាក់ទៀតថា" ឃើញស្នាមញញឹមរបស់កូនក្មេង ខ្ញុំពិតមែនមានសុភមង្គលណាស់" ៕